អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jun-2012, 15:46
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ

កាលបរិច្ឆេទ៖ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២

ពី៖ ឯកឧត្តម គង់ ស្រ៊ឹម
ប្រធានអង្គជំនុំជម្រះតុលាការកំពូល

ជូនចំពោះ: អង្គជំនុំជម្រះសាលាដំបូង
អង្គបុរេជំនុំជម្រះ
ការិយាល័យសហចៅក្រមស៊ើបអង្កេត
ការិយាល័យសហព្រះរាជអាជ្ញា
អង្គភាពគាំពារការការពារក្តី
មេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច
អង្គភាពជនរងគ្រោះ
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ផ្នែកគ្រប់គ្រងតុលាការ
ប្រធានការិយាល័យរដ្ឋបាលស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល

**កម្មវត្ថុ៖ ការពិនិត្យមើលឡើងវិញនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុត ដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១**

## I. សេចក្ដីផ្ដើម

១. អនុលោមតាមមាត្រា ១២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង (វិសោធនកម្មលើកទី ១)("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទឯកសារ") អង្គជំនុំជម្រះតុលាការកំពូលក្នុងនាមជា "ការិយាល័យតុលាការចុងក្រោយ" ដែលបានទទួលសំណុំឯកសារនេះក្នុងសំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក ("សំណុំឯកសារនៃសំណុំរឿង ០០១") បានទទួលភារកិច្ចពិនិត្យឡើងវិញទៅលើឯកសារទាំងអស់ ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាឯកសារសម្ងាត់ ឬសម្ងាត់បំផុតនាពេលបច្ចុប្បន្ន ដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង ០០១ សម្រាប់គោលបំណងនៃការចាត់ប្រភេទឡើងវិញ ទៅលើឯកសារទាំងនោះ ថាជាឯកសារសាធារណៈ តាមដែលអាចធ្វើទៅបាន។ អនុស្សរណៈនេះមានបំណងថែងអំពីគោលការណ៍ណែនាំទូទៅ នៅក្នុងគោលការណ៍ដែលបានស្នើឡើង ហើយស្នើសុំយោបល់ពីភាគីពាក់ព័ន្ធនឹងចំណាត់ប្រភេទឯកសារឡើងវិញ។

២. ការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ នឹងត្រូវធ្វើឡើង ជា បីដំណាក់កាល។ ទីមួយ យោងតាមអនុស្សរណៈនេះ អង្គជំនុំជម្រះបានបង្ហាញនូវគោលការណ៍ណែនាំ ក្នុងការស្នើសុំយោបល់ពីភាគី ផ្នែក និងអង្គភាពដែលពាក់ព័ន្ធ។ ទីពីរ បន្ទាប់ពីបានការពិនិត្យលើការអង្កេតរបស់ភាគី អង្គជំនុំជម្រះនឹងផ្សព្វផ្សាយគោលការណ៍ចុងក្រោយសម្រាប់ការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ ជាមួយនឹងបញ្ជីឯកសារសម្ងាត់ និងសម្ងាត់បំផុត ក្នុងសំណុំរឿង ០០១។ ជាមួយគ្នានេះដែរ អង្គជំនុំជម្រះនឹងស្នើសុំយោបល់បន្ថែមទៀត ពីភាគីដែលជាប់ពាក់ព័ន្ធទៅនឹងឯកសារ ឬប្រភេទជាក់លាក់ណាមួយ។ ទីបី អង្គជំនុំជម្រះ នឹងធ្វើការពិនិត្យឡើងវិញលើឯកសារដែលសម្ងាត់ និងសម្ងាត់បំផុត ហើយនឹងសម្រេចលើការចំណាត់ឯកសារ ដោយយោងទៅតាមគោលការណ៍ណែនាំចុងក្រោយនេះ។

## II. គោលការណ៍ណែនាំស្ដីពីចំណាត់ប្រភេទឯកសារឡើងវិញ

៣. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ក្នុងចំនោមឯកសារសម្ងាត់ចំនួន ១២.៥១៤ នៅក្នុងសំណុំរឿង ០០១ មានឯកសារចំនួន ៩.៧៥៩ ដែលត្រូវបានដាក់ដោយសហចៅក្រមស៊ើបអង្កេត។ អង្គជំនុំជម្រះតុលាការកំពូល សម្រេចថា ភាពសម្ងាត់ស្ដីពីការស៊ើបអង្កេតរបស់តុលាការដែលកំពុងបន្ត ជាពិសេស ចំពោះឯកសារដែលបានរៀបរាប់នៅក្នុង មាត្រា ៥.១(ក), (ខ), (គ)

និង (ច) នៃ សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ឯកសារ គឺជាបញ្ហាសំខាន់ដែលត្រូវដោះស្រាយក្នុងគោលបំណងដើម្បីដាក់ចំណាត់ប្រភេទឯកសារឡើងវិញ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលស្នើសុំ ការផ្តល់យោបល់ស្តីពីភាពចាំបាច់ចំពោះភាពសម្ងាត់នៃឯកសារនេះនៅក្នុងដំណាក់កាលនៃសំណុំរឿង ០០១ នេះ។

៤. បន្ថែមពីលើការពិចារណាចំពោះកិច្ចស៊ើបអង្កេតរបស់តុលាការ និងដោយពិចារណាទៅលើមាត្រា ៤ មាត្រា ៥ និងមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ អង្គជំនុំជម្រះតុលាការកំពូលដាក់នូវគោលការណ៍ដូចខាងក្រោម ដើម្បីប្រើប្រាស់នៅក្នុងអំឡុងពេលនៃការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ និងការរៀបចំសំណុំរឿង ០០១ ដែលកំពុងប្រព្រឹត្តទៅ៖

ក. ឯកសារខាងក្រោមត្រូវនៅជា ឬត្រូវចាត់ប្រភេទជាឯកសារសម្ងាត់៖

i. ឈ្មោះ និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់ជនរងគ្រោះ ដែលពុំមែនជាដើមបណ្តឹងរដ្ឋប្បវេណី មាននៅក្នុងសំណុំរឿង ដែលព័ត៌មាននេះត្រូវបានដាក់បញ្ចូលនៅក្នុងពាក្យបណ្តឹងរបស់ជនរងគ្រោះ។

ii. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក និងកំណត់ហេតុសោតទស្សន៍នៃកិច្ចសវនាការដែលត្រូវបានធ្វើ*ជាសម្ងាត់* លើកលែងតែហេតុផលសម្រាប់ការរក្សាការសម្ងាត់ ដែលលែងមានសុពលភាពតទៅទៀត។

iii. ឯកសារដែលមាននៅក្នុងសំណុំរឿង ហើយដែលត្រូវបានចាត់ថ្នាក់ជាសម្ងាត់។

ខ. ឯកសារដែលត្រូវបានចាត់ជាសម្ងាត់បំផុត ជាគោលការណ៍ នឹងត្រូវរក្សាទុកចំណាត់ថ្នាក់នេះដដែលនោះ រួមមាន:

i. សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ

ii. ឯកសារ និងព័ត៌មានដែលអាចស្ថិតនៅក្រោមវិធានការការពារ

iii. ព័ត៌មានពាក់ព័ន្ធនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ

iv. ឯកសារនៅពេលមូលហេតុសម្រាប់ចំណាត់ថ្នាក់ឯកសារជាសម្ងាត់បំផុតនៅតែមានសុពលភាព

គ. ឯកសារណា ឬផ្នែកនៃឯកសារនោះ ដែលមិនបានស្ថិតនៅក្នុងកថាខណ្ឌ (ក) ឬ(ខ) ខាងលើ ជាគោលការណ៍ ត្រូវតែដកចំណាត់ថ្នាក់។

ឃ. ប្រសិនបើឯកសារណាមួយដែលមានមួយផ្នែកជាផ្នែកសាធារណៈ និងមួយផ្នែកទៀតត្រូវបានចាត់ប្រភេទជាឯកសារសម្ងាត់ ឬសម្ងាត់បំផុត មាត្រា ៣.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារត្រូវយកមកអនុវត្ត។

ង. ឯកសារសាធារណៈមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ ក្នុងករណីដែលឯកសារទាំងនោះ (ក) ត្រូវបានការពារដោយច្បាប់រក្សាសិទ្ធិជាធរមាន ឬ (ខ) "ស្ថិតក្រោមការឯកភាពជាមួយតតិយជន ដែលហាមឃាត់មិនឲ្យផ្សព្វផ្សាយ [...] លើកលែងតែមានការអនុញ្ញាតពីសំណាក់តតិយជន"[1]។

ច. អង្គជំនុំជម្រះតុលាការកំពូលសូមរក្សានូវសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្ម ដោយអនុលោមតាមវិធានផ្ទៃចំពោះការទម្លាយព័ត៌មានដែលមានចំណាត់ថ្នាក់ ដោយពុំមានការអនុញ្ញាត ។

ឆ. ភាគីពាក់ព័ន្ធណាមួយ រួមទាំងការិយាល័យសហព្រះរាជអាជ្ញា អង្គភាពគាំពារការការពារក្តីតំណាងជនជាប់ចោទក្នុងសំណុំរឿង ០០១ និងអង្គភាពជនរងគ្រោះតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឬ ផ្នែកកិច្ចការសាធារណៈ អាចស្នើសុំឲ្យដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញទៅលើឯកសារទាំងឡាយណា ដែលជាឯកសារសម្ងាត់ ឬសម្ងាត់បំផុត បន្ទាប់ពីការបញ្ចប់នីតិវិធីនៃការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនេះ។ ក្នុងករណីបែបនេះ ភាគីពាក់ព័ន្ធគប្បីបង្ហាញអំពីកាលៈទេសៈប្រែប្រួលដែលបញ្ជាក់ពីហេតុផលសមស្រប ក្នុងការចាត់ប្រភេទឯកសារជាថ្មីឡើងវិញនេះ។

---

[1] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ, មាត្រា ១២.៣។

## III. យោបល់ពីភាគី អង្គជំនុំជម្រះ និងអង្គភាពផ្សេងៗនៃតុលាការ

៥. ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលអញ្ជើញភាគីដែលពាក់ព័ន្ធនឹងអនុស្សរណៈនេះផ្តល់យោបល់ស្តីអំពីគោលការណ៍ណែនាំដែលអង្គជំនុំជម្រះបានស្នើឡើង សម្រាប់ចំណាត់ប្រភេទឯកសារឡើងវិញ និង សម្រាប់ការសម្ងាត់ដែលមានចំពោះកិច្ចស៊ើបសួររបស់តុលាការ ត្រឹមថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២។ ពាក់ព័ន្ធនឹងស្ថានភាពនៃសំណុំរឿង ០០១ អង្គជំនុំជម្រះស្នើសុំការជួយជ្រោមជ្រែងពីអង្គភាពគាំពារការការពារក្តី និងអង្គភាពជនរងគ្រោះ ក្នុងការធានាឱ្យមាននូវការពិគ្រោះយោបល់ជាមួយមេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ យោបល់ណាមួយដែលត្រូវបានដាក់ក្រោយ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ នឹងត្រូវបានអង្គជំនុំជម្រះធ្វើការពិចារណាទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។